28/04/23

603

28-11-22

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍បាត់ដំបង**

**សាលដីកា**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងលេខ: ៣៨៣

ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២

**សាលដីកាលេខ: ៤៨៧(ខ)**

ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍បាត់ដំបង**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២

ដោយមានសមាសភាពអង្គជំនុំជម្រះ ដូចខាងក្រោម ៖

១.លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២.ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា

៣.លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងឧទ្ធរណ៍លេខ ៤៦២៦ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted] ជឿន ចំពោះសាលក្រមព្រហ្មទណ្ឌលេខ ៩៥៥ "ក" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមាន៖

១-ជនជាប់ចោទឈ្មោះ[redacted] ជឿន ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ មានទីលំនៅបច្ចុប្បន្ន[redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ពោះម៉ាយ មានកូនចំនួន ០១ នាក់ (ទោសពីមុនធ្លាប់ជាប់ពន្ធនាគាររយៈពេល ០៣ខែ ករណីប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀន)។ (ក្នុងឃុំ) (ជាអ្នកប្តឹងឧទ្ធរណ៍)

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៦០ ត.ព្រ/២១/១២.០៦.២០២១។

មានលោក[redacted]សុខា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។



Scanned with CamScanner

**ជាប់ចោទពីបទ:** ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ជនជាប់ចោទឈ្មោះ [redacted] សុភី ហៅ មុំ ភេទស្រី អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីលំនៅបច្ចុប្បន្ន [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" (ទោសពីមុនគ្មាន)។ (គេចខ្លួន)

ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៥០២ ត.ព្រ/៣០.០៨.២០២១។

៣-ជនជាប់ចោទឈ្មោះ [redacted] សុខឿន ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីលំនៅបច្ចុប្បន្ន [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ ស៊ុយ យ៉ា "រ" ពោះម៉ាយ (ទោសពីមុនគ្មាន)។ (គេចខ្លួន)

ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៥០៤ ត.ព្រ/៣០.០៨.២០២១។

៤-ជនជាប់ចោទឈ្មោះ [redacted] យ៉ាន ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីលំនៅបច្ចុប្បន្ន [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" (ទោសពីមុនគ្មាន)។ (គេចខ្លួន)

ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៥០៣ ត.ព្រ/៣០.០៨.២០២១។

**ជាប់ចោទពីបទ:** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**អំពីអង្គហេតុ៖**

-អញ្ញត្តិជននៅប្រទេសថៃបានផ្ញើកញ្ចប់គ្រឿងញៀន តាមក្រុមហ៊ុនដឹកជញ្ជូន ជេអិនធី មានទីតាំងនៅភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង។ ដោយមានការសង្ស័យលើកញ្ចប់ថាជាគ្រឿងញៀនក្រុមហ៊ុនបានរាយការណ៍ទៅសមត្ថកិច្ចឱ្យឃ្លាំមើលអ្នកទទួលកញ្ចប់បញ្ញើនេះ។ នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ឈ្មោះ [redacted] ជឿន ភេទប្រុស អាយុ ៣៦ឆ្នាំ បានមកទទួលកញ្ចប់បញ្ញើ ហើយត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងដកហូតគ្រឿងញៀនចំនួន ១៣៧១.២៧ក្រាម ម៉ូតូហុងដាឌ្រីម ០១គ្រឿង ជារបស់ឈ្មោះ [redacted] សុភី ហៅ មុំ ទូរស័ព្ទដៃ០១គ្រឿង របស់ឈ្មោះ [redacted] សុខឿន ជញ្ជីងថ្លឹងថ្នាំញៀន ចំនួន០១ រួមទាំងសម្ភារៈផ្សេងៗទៀតវត្ថុតាងមានដូចក្នុងកំណត់ហេតុចាប់យកផងដែរ។ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជឿន បានសារភាពថាគ្រឿងញៀនទាំងនេះ គឺឈ្មោះ [redacted] សុភី ជាអ្នកទូរស័ព្ទបញ្ជាទិញពីជនមិនស្គាល់ឈ្មោះនៅប្រទេសថៃ ហើយប្រើឈ្មោះ [redacted] សុខឿន ឱ្យទៅទទួលតែត្រូវឈ្មោះ [redacted] សុខឿន ប្រើខ្លួនបន្ត។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៩៥៥ "ក" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ដែលបានសម្រេច:

១-ផ្តន្ទាទោសដាក់ពន្ធនាគារ៖ ឈ្មោះ [redacted] ជឿន ដែលមានសវតាជាតិដូចខាងលើ រយៈពេល ៣០ (សាមសិប)ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន និងពិន័យជាប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល បង់ចូលជាថវិការដ្ឋ។



Scanned with CamScanner

ពីបទ "ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន"។

២-ផ្តន្ទាទោសដាក់ពន្ធនាគារៈ

២-១-ឈ្មោះ [redacted] សុភី ហៅ មុំ ដែលមានសាវតាជាតិដូចខាងលើ

២-២-ឈ្មោះ [redacted] សុខឿន ដែលមានសាវតាជាតិដូចខាងលើ

២-៣-ឈ្មោះ [redacted] យ៉ាន ដែលមានសាវតាជាតិដូចខាងលើ

ក្នុងម្នាក់ៗរយៈពេល ៣០(សាមសិប)ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនបានយកមកអនុវត្តទោសក្នុងពន្ធនាគារ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៨០.០០០.០០០(សែសិបលាន)រៀល បង់ចូលជាថវិការដ្ឋ។

ពីបទៈជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

៣-វត្ថុតាង (ដូចក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ២៥៦ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តបាត់ដំបង) រួមមាន ៖

៣-១-ថ្នាំញៀនក្រាមម្សៅប្រភេទ មេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក ឬអាយ) ទម្ងន់ ១.២៣៤,៦៥ ក្រាម ជញ្ជីងចំនួន ០១គ្រឿង និងសម្ភារៈសម្រាប់ប្រើប្រាស់ថ្នាំញៀន ត្រូវរឹបអូសយកទៅបំផ្លាញចោល ។

៣-២-ម៉ូតូ ស៊េរីឆ្នាំ២០១៨ ចំនួន ០១គ្រឿង និងទូរស័ព្ទដៃ ចំនួន ០១គ្រឿង(ចាស់) ត្រូវរឹបអូសចូលជាសម្បត្តិរដ្ឋ។

៤-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនៈ ឈ្មោះ [redacted] សុភី ហៅ មុំ, ឈ្មោះ [redacted] សុខឿន និងឈ្មោះ [redacted] យ៉ាន តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៤៦២៦ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ជឿន ចំពោះសាលក្រមព្រហ្មទណ្ឌលេខ ៩៥៥ "ក" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ប្តឹងត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ របាយការណ៍របស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបង

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍។

-ជនជាប់ចោទឈ្មោះ [redacted] ជឿន បានឆ្លើយថាៈ ការដែលខ្ញុំប្តឹងមកនេះដោយសារមិនសុខចិត្ត ចង់ឱ្យតុលាការជួយបន្ធូរបន្ថយទោស ដោយខ្ញុំបានទទួលស្គាល់អង្គហេតុហើយ ថ្នាំញៀនខ្ញុំបានទៅយកនៅក្រុមហ៊ុនដឹកជញ្ជូន J&T ដោយឈ្មោះ [redacted] សុភី, [redacted] សុខឿន និងឈ្មោះ [redacted] យ៉ាន ជាអ្នកណែនាំឱ្យទៅយកថាជាកេះទឹកក្រូច។ ដោយកាលនៅសាលាដំបូងខ្ញុំបានឆ្លើយថាជាទៅយកថ្នាំញៀន ដល់សាលាឧទ្ធរណ៍ឆ្លើយថាទឹកក្រូច ដោយសមត្ថកិច្ចឱ្យយាយថាទៅយកគ្រឿងញៀន ដោយពេលទៅយកឈ្មោះ [redacted] សុខឿន ឱ្យទូរស័ព្ទរបស់គេ។ ខ្ញុំមានមុខរបរធ្វើការសំណង់បានមួយថ្ងៃ ៤០,០០០រៀល ដោយពេលទៅយកគឺប៉េអឹមបានចាប់ខ្លួន ខ្ញុំនិងឆែកក្នុងកេះឃើញមានជញ្ជីងនៅក្នុងនឹង ពីផ្ទះខ្ញុំទៅកន្លែងយកឥវ៉ាន់ចំងាយប្រហែល២ ទៅ៣ គីឡូម៉ែត្រ ពេលដែលចាប់ខ្លួនហើយខ្ញុំបាននាំទៅរកអ្នកដែលបញ្ជាឱ្យខ្ញុំមកយកថ្នាំញៀនដែរ ប៉ុន្តែពួកគេគេចខ្លួនបាត់អស់ហើយ ខ្ញុំរាល់ថ្ងៃមានកូនម្នាក់រៀនថ្នាក់ទី១ ហើយខ្ញុំជាបុរសពោះម៉ាយ ហើយខ្ញុំបានរៀនត្រឹមថ្នាក់ទី៩។ ពេលដែលគេឱ្យខ្ញុំទៅយកអីវ៉ាន់នៅ J&T ដោយឈ្មោះ [redacted] សុខឿន និងឈ្មោះ [redacted] សុភី ដោយសន្យាថាឱ្យប្រាក់មកខ្លួនចាយ តែពេលទៅយកអីវ៉ាន់នឹងមិនបានប្រាក់ឈ្នួលទេ។



Scanned with CamScanner

-តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជឿន ថ្វីត្បិតតែមិនបានសារភាពនូវអំពើរបស់ខ្លួនយ៉ាងច្បាស់លាស់ទេ ប៉ុន្តែបើតាមសកម្មភាពនិងចម្លើយសារភាពរបស់ខ្លួនកន្លងមកឃើញថា អំពើរបស់ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសជួញដូរថ្នាំញៀន ដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដូច្នេះយើងតំណាងមហាអយ្យការស្នើសុំរក្សាការចោទប្រកាន់លើជនជាប់ចោទដដែល និងស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សា ក៏ដូចជាចៅក្រមប្រឹក្សា ពិនិត្យនិងសម្រេចទៅតាមផ្លូវច្បាប់។

-លោក [redacted] សុខា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថាៈ ទាក់ទងនឹងបទចោទប្រកាន់របស់កូនក្តីខ្ញុំបាទពីបទៈ ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ហើយទាក់ទងនិងការសួរដេញដោលនាពេលសវនាការនេះក៏ដូចជាឯកសារនៅក្នុងសំណុំរឿង កូនក្តីខ្ញុំបាទក៏បានសហការជាមួយសមត្ថកិច្ចទាក់ទងនឹងចម្លើយ និងស្វែងរកជនដែលពាក់ព័ន្ធដទៃទៀត ប៉ុន្តែជនដែលពាក់ព័ន្ធគាត់បានដឹងខ្លួនក៏រត់គេចខ្លួនអស់ ដូចនេះអង្គហេតុសំខាន់ៗខ្ញុំពិនិត្យឃើញថាក៏មានវិមតិសង្ស័យដែរនូវភាពចេតនារបស់ជនជាប់ចោទ ដោយយោងតាមមាត្រា ៣ មាត្រា ៤ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ អំពីវិមតិសង្ស័យ តែទោះបីជាយ៉ាងណាក៏ដោយកូនក្តីខ្ញុំបាទក៏បានសារភាព និងទទួលស្គាល់នូវកំហុសរបស់ខ្លួន ហើយមួយវិញទៀតទាក់ទងនិងឈ្នួល ២០,០០០រៀល ក៏គាត់មិនទាន់នៅឡើយ ហើយកម្រិតជីវភាពរបស់គាត់ជាកម្មករ ហើយចំពោះការផ្តន្ទាទោសរបស់តុលាការក៏មានស្ថានភាពធ្ងន់ធ្ងរលើសពីសមត្ថភាពរបស់ជនជាប់ចោទដែរ ដូចនេះខ្ញុំបាទគាត់តែស្នើសុំឱ្យប្រធានក្រុមប្រឹក្សា ក៏ដូចជាចៅក្រមប្រឹក្សាមេត្តាពិចារណា និងបន្ធូរបន្ថយទោសដល់ជនជាប់ចោទ។

-ជនជាប់ចោទឈ្មោះ [redacted] ជឿន បានធ្វើការសំណូមពរចុងក្រោយថាៈ សុំឱ្យលោកតុលាការជួយបន្ធូរទោស ដើម្បីឆាប់បានទៅជួបកូនវិញ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានសុំរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍បាត់ដំបង

១-យល់ឃើញថា បណ្តឹងឧទ្ធរណ៍លេខ ៤៦២៦ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ជឿន ចំពោះសាលក្រមព្រហ្មទណ្ឌលេខ ៩៥៥ "ក" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបងអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៤៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៣៧៣, ៣៧៥, ៣៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ជនជាប់ចោទបានឆ្លើយនាពេលសវនាការថាៈ ការដែលខ្ញុំប្តឹងមកនេះដោយសារមិនសុខចិត្ត ចង់ឱ្យតុលាការជួយបន្ធូរបន្ថយទោស ដោយខ្ញុំបានទទួលស្គាល់អង្គហេតុហើយ ថ្នាំញៀនខ្ញុំបានទៅយកនៅក្រុមហ៊ុនដឹកជញ្ជូន J&T ដោយឈ្មោះ [redacted] សុភី [redacted] សុខឌឿន និងឈ្មោះ [redacted] យ៉ាន ជាអ្នកណែនាំឱ្យទៅយកថាជាកេះទឹកក្រូច។ ដោយពេលទៅយក ក៏ប៉េអឹមបានចាប់ខ្លួនខ្ញុំនិងឆែកក្នុងកេះឃើញមាន

ជញ្ជីងនៅក្នុងនឹង។ ពេលដែលចាប់ខ្លួនហើយខ្ញុំបាននាំ ទៅរកអ្នកដែលបញ្ជាឱ្យខ្ញុំមកយកថ្នាំញៀនដែរ ប៉ុន្តែពួកគេគេចខ្លួនបាត់អស់ហើយ។ ពេលដែលគេឱ្យខ្ញុំទៅ យកអីវ៉ាន់នៅ J&T ដោយឈ្មោះ [redacted] សុខខឿន និងឈ្មោះ [redacted] សុភី ដោយសន្យាថាឱ្យប្រាក់មកខ្លួនចាយ តែពេលទៅយកអីវ៉ាន់នឹងមិនបានប្រាក់ឈ្នួលទេ។ ចំណែកឯ សេចក្តីសន្និដ្ឋានរបស់លោក [redacted] សុខា ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទក៏បានលើកឡើងថា ទាក់ទងនិងការសួរដេញដោលនាពេលសវនាការ នេះក៏ដូចជាឯកសារនៅក្នុងសំណុំរឿង កូនក្តីខ្ញុំបាទក៏បានសហការជាមួយសមត្ថកិច្ចទាក់ទងនឹងចម្លើយ និងស្វែងរកជនដែលពាក់ព័ន្ធដ៏ទៃទៀត ប៉ុន្តែជនដែលពាក់ព័ន្ធគាត់បានដឹងខ្លួនក៏រត់គេចខ្លួនអស់ ដូចនេះអង្គហេតុសំខាន់ៗខ្ញុំពិនិត្យឃើញថាក៏មានវិមតិសង្ស័យដែរនូវភាពចេតនារបស់ជនជាប់ចោទ ដោយយោងតាមមាត្រា ៣ មាត្រា ៤ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ អំពីវិមតិសង្ស័យ តែទោះបីជាយ៉ាងណាក៏ដោយកូនក្តីខ្ញុំបាទក៏បានសារភាព និងទទួលស្គាល់នូវកំហុសរបស់ខ្លួនហើយមួយវិញទៀតទាក់ទងនិងឈ្នួល ២០,០០០រៀល ក៏គាត់មិនទាន់នៅឡើយ ហើយកម្រិតជីវភាពរបស់គាត់ជាកម្មករ ហើយចំពោះការផ្តន្ទាទោសរបស់តុលាការក៏មានស្ថានភាពធ្ងន់ធ្ងរលើសពីសមត្ថភាពរបស់ជនជាប់ចោទដែរ។ ដូចនេះ ខ្ញុំបាទគាត់តែស្នើសុំឱ្យប្រធានក្រុមប្រឹក្សា ក៏ដូចជាចៅក្រមប្រឹក្សាមេត្តាពិចារណា និងបន្ធូរបន្ថយទោសដល់ជនជាប់ចោទ។ តាមចម្លើយរបស់ជនជាប់ចោទ និងការលើកឡើងរបស់លោកមេធាវីខាងលើ ក្រុមប្រឹក្សាជំនុំជម្រះមិនអាចពិចារណាបានទេ ព្រោះថាទីមួយ អង្គហេតុនៃរឿងនេះគឺជាបទល្មើសជាក់ស្តែងដែលសមត្ថកិច្ចបានធ្វើការបង្ក្រាប និងចាប់បាននៅនឹងកន្លែងតែម្តង ទោះបីជាជនជាប់ចោទថា បានស៊ីឈ្នួលយកឲ្យអ្នកដទៃក្នុងតម្លៃ២០,០០០(ពីរម៉ឺន)រៀលនោះមិនមានភស្តុតាងណាមួយឲ្យតុលាការអាចជឿជាក់បាននោះទេ ទីពីរ បរិមាណនៃថ្នាំញៀនដែលជនជាប់ចោទបានទៅទទួលយកនោះគឺមានចំនួនរហូតទៅដល់ ៩៧៣,១៨ក្រាម បរិមាណខាងលើសាលាដំបូងបានគណនាឃើញថាមានបរិមាណច្រើន បើតាមពិនិត្យតាមអង្គហេតុដែលគប្បីធ្វើការផ្តន្ទាទោសរហូតដល់មួយជីវិត។ ហេតុដូច្នេះ ការសម្រេចរបស់សាលាដំបូងខេត្តបាត់ដំបងដោយធ្វើការផ្តន្ទាទោសត្រឹម៣០ឆ្នាំនោះ ឃើញថាត្រឹមត្រូវតាមច្បាប់ហើយ។

៣-យល់ឃើញថា សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបងថា: ឆ្លងតាមការស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ជឿន ថ្វីត្បិតតែមិនបានសារភាពនូវអំពើរបស់ខ្លួនយ៉ាងច្បាស់លាស់ទេ ប៉ុន្តែបើតាមសកម្មភាពនិងចម្លើយសារភាពរបស់ខ្លួនកន្លងមកឃើញថា អំពើរបស់ជនជាប់ចោទ ពិតជាបានប្រព្រឹត្តបទល្មើសជួញដូរថ្នាំញៀន ដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដូច្នេះយើងតំណាងមហាអយ្យការស្នើសុំរក្សាការចោទប្រកាន់លើជនជាប់ចោទដដែល និងស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សា ក៏ដូចជាចៅក្រមប្រឹក្សា ពិនិត្យនិងសម្រេចទៅតាមផ្លូវច្បាប់។ ចំណុចនេះ ក្រុមប្រឹក្សាជំនុំជម្រះអាចពិចារណាបានដូចទៅនឹងសម្អាងហេតុខាងលើ។

៤-យល់ឃើញថា ខ្លឹមសារនៃសាលក្រមព្រហ្មទណ្ឌលេខ ៩៥៥ "ក" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវតាមច្បាប់ហើយ។

## ហេតុដូច្នេះ

## សម្រេច

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៦២៦ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ជឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយទាស់ទៅនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩៥៥ "ក" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល។



Scanned with CamScanner

សាលដីកានេះជំនុំជម្រះនាសវនាការជាសាធារណៈ នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោ[redacted] ជឿន និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
| --- | --- | --- |
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| [redacted] | [redacted] | [redacted] |

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៣រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

បាត់ដំបង ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner